INNOVATION FOR CHANGE
EAST ASIA



# ក្មេងស្រីកម្ពុជា
## ក្នុងភូមិដែល
## ជន់លិចលង់
## ដោយសារតែ
## ទំនប់វារីអគ្គិសនី

រឿងរ៉ាវ
អំពីផលប៉ះពាល់ចេញពី
គម្រោងខ្សែក្រវ៉ាត់និងផ្លូវរបស់
ប្រទេសចិន

ថ្ងៃមួយ ខ្ញុំបានចូលព្រៃរកផ្សិត និងបេះបាយដំណើបតាមទម្លាប់។ ពេលដែលកំពុងតែដាក់ផ្សិតទៅក្នុងកាផា ខ្ញុំស្រាប់តែឮពូម្នាក់ស្រែកឱ្យជួយ ព្រោះពស់បានចឹកជើងរបស់គាត់។ ដោយសារតែជើងគាត់ឡើងហើម អ្នកទៅរកផ្សិតជាមួយគ្នាក៏ទំពារស្លឹកឈើព្រួសលើរបួសគាត់ដើម្បីបន្សាបពិស។

តែគាត់ត្រូវយកទៅសង្គ្រោះនៅមន្ទីរពេទ្យខេត្តភ្លាមៗ ដោយសារស្ថានភាពគាត់កាន់តែធ្ងន់ធ្ងរ។ ខ្ញុំឈរភ្លឹក ព្រោះចិត្តខ្ញុំស្រមៃនឹកដល់ក្តីស្រមៃធ្វើជាគ្រូពេទ្យតាំងពីក្មេង។




ពេលខ្ញុំនៅតូច ឱ្យតែទំនេរពីម៉ោងរៀន ខ្ញុំតែងជួយស្រោចទឹក និងបេះបន្លែម៉ែខ្ញុំ នៅឯចម្ការក្បែរផ្ទះ។
ពុកម៉ែខ្ញុំដាំដំណាំមិនហត់ទេ! ចម្ការដំណាំគាត់ល្អណាស់ ព្រោះតែបានជីរជាតិហូរពីទន្លេសេសានមក!
ដោយសារផ្ទះយើងនៅក្បែរទន្លេ ពុកខ្ញុំក៏ចូលចិត្តទៅនេសាទនៅទន្លេនោះរៀងរាល់ថ្ងៃ។


ពុក! ខ្ញុំឮគេថា ត្រីនៅទន្លេយើងថ្លៃ ហើយ
ឆ្ងាញ់ជាងគេនៅស្រុកខ្មែរ។ មែនទេ ពុក?
ត្រូវហើយ!កូនបានលុយទៅរៀនរាល់ថ្ងៃក៏ដោយសារ
តែត្រីហ្នឹងដែរ។ វាជាប្រភពចំណូលដ៏ធំមួយ
សម្រាប់គ្រួសារយើង។
តែ...ពុកត្រូវទុកត្រីនោះឱ្យកូនញ៉ាំដែរណា៎!


ពុកម៉ែខ្ញុំ និងគ្រួសារពូនងផ្សេងទៀតតែងតែចូលព្រៃដើម្បីចៀវជ័រ ឬរកឃ្មុំ។ វាជាផ្នែកមួយនៃប្រពៃណីជនជាតិយើង។ តែរាល់លើកឱ្យតែខ្ញុំទទូចសុំទៅតាមគាត់ គាត់តែងគំរាមខ្ញុំថា មានខ្លាព្រៃមួយនៅចាំស៊ីកូនក្មេងដូចខ្ញុំ។


ជារៀងរាល់ឆ្នាំ អ្នកភូមិខ្ញុំតែងតែជុំគ្នាដើម្បីធ្វើបុណ្យភូមិក្បែរទន្លេពេលច្រូតកាត់រួច។ តាមទំនៀមទម្លាប់យើងធ្វើពិធីនេះដើម្បីរំលឹកគុណដល់សត្វគោក្របី និងធម្មជាតិដែលបានជួយឱ្យស្រែចម្ការ និងដំណាំយើងហុចផលល្អ។
យកស្អីមកខ្លះហ្នឹង ផា?
ខ្ញុំមានតែស្រាពាងមកថ្វាយទេឆ្នាំនេះ។
គ្មានអីច្រើនទេមីង! ខ្ញុំយកមាន់ស្ងោរពីរ និងផ្លែឈើខ្លះៗមកសែន
ដោយសារខ្ញុំទទួលបានភោគផលល្អឆ្នាំនេះ។


ហើយប្រសិនបើមាននរណាស្លាប់នៅក្នុងភូមិ ចាស់ៗនៅក្នុងភូមិតែងយកសពទៅកប់កន្លែងដី កប់សពរបស់ជនជាតិយើង។ ចាស់ៗតែងតែយករបស់របររបស់សពដាក់ក្នុងក្រឡ ហើយដាក់ទៅក្នុងផ្នូរនោះ។ យើងធ្វើពិធីឱ្យព្រលឹងដូនតាយើងរាល់ឆ្នាំ ព្រោះយើងជឿថាគាត់នឹងនៅតាមការពារយើង និង សហគមន៍យើង។


នៅកន្លែងបុណ្យសពនោះខ្ញុំឮចាស់ៗជជែកគ្នាពីគម្រោងវារីអគ្គិសនីរបស់ក្រុមហ៊ុនចិនដែលកសាងនៅខ្សែទឹកខាងក្រោម។ម្នាក់ៗខ្លាចបាត់បង់ភូមិស្រែគរនិងទំនៀមទំលាប់យើងណាស់ ដោយសារយើងបានអនុវត្តវាច្រើនជំនាន់មកហើយ។ ដូច្នេះហើយចាស់ៗទាំងនោះក៏បន់ស្រន់ឱ្យដូនតាយើងបញ្ឈប់គម្រោងអភិវឌ្ឍនោះ។
សូមបួងសួងដល់ជីដូនជីតា និងអារក្សអ្នកតាថែរក្សាទីនេះទាំងអស់ សូមជួយឱ្យ គម្រោងវារីអគ្គិសនៅបរវៀសចៀសឆ្ងាយពីភូមិទៅ! សូមជួយរក្សាកូនចៅទំនៀមទម្លាប់ និងសហគមន៍យើងផង!
សូមជួយរក្សាកូនចៅផង!


ពីរឆ្នាំក្រោយមក!
ខ្ញុំបានជាប់លេខមួយនៅឆមាសទីមួយ ក្នុងថ្នាក់ទី៨នេះ។ ខ្ញុំសប្បាយចិត្ត ហើយប្រញាប់យករឿងនេះទៅប្រាប់ម៉ែ តែពេលដែលខ្ញុំដើរចេញពីសាលា ខ្ញុំឃើញក្រុមប៉ូលិស មេឃុំ ជជែកជាមួយនឹងចាស់ៗតំណាងជនជាតិពូនង។
ពួកយើងមកប្រាប់ដំណឹងល្អដល់ពូមីងទាំងអស់គ្នា។ យើងបានសាងសង់ផ្ទះសម្រាប់គ្រួសារទាំងអស់ហើយ។ ផ្ទះនោះធំៗណាស់ ហើយយើងជឿថា ពូមីងនឹងមានជីវិតល្អប្រសើរនៅទីនោះ។
ឮហើយ ខ្ញុំចង់ដឹងណាស់។ ខ្ញុំក៏ដើរសំដៅទៅផ្ទះយ៉ាងលឿន ដើម្បីសួរម៉ែខ្ញុំ។
ម៉ែ! ខ្ញុំឃើញមនុស្សជុំៗនៅក្បែរសាលា អម្បាញ់មិញ។ មានរឿងអីមែនទេ ម៉ែ?
អូហ៍កូន! ប៉ូលិស និងមេឃុំមកប្រាប់ពួកយើង ឱ្យចេញទៅនៅភូមិដែលគេសាងសង់ឱ្យហ្នឹងណាកូន ព្រោះគេសង់ទំនប់ចិននោះរួចរាល់ហើយ ហើយគេត្រូវសម្ពោធវាឆាប់ៗ។
យើងពិតជាត្រូវចេញមែនឬម៉ែ? ក្ដីស្រមៃខ្ញុំនិងក្មេងៗឯទៀតនឹងទៅជាយ៉ាងម៉េចទៅ?
កុំបារម្ភពេកកូន!គ្មាននរណាចង់ចេញពីភូមិយើងចាស់នេះទេ ព្រោះយើងធំមកជាមួយទឹកដីដូនតាយើងនេះហើយ។


បន្ទាប់ពីអាជ្ញាធរមកប្រាប់ឱ្យមនុស្សសហគមន៍យើងទៅនៅភូមិថ្មី មនុស្សជាច្រើនចាប់ផ្ដើមជជែកពី ការសម្រេចចិត្តរបស់ពួកគេ។
ខ្ញុំគិតថា យើងគួរតែទៅនៅភូមិថ្មីនោះទៅ ដើម្បីកុំឱ្យមានបញ្ហាវែងឆ្ងាយ។
ទេ! នេះជាទឹកដីដូនតាយើងរស់នៅរាប់ជំនាន់ហើយ! យើងមិនចេញទៅណាដាច់ខាត!
ប៉ុន្តែ គេព្រមានយើងថា បើយើងមិនចេញពីភូមិនេះទេគេនឹងបិទទំនប់ពន្លិចភូមិយើងហើយ។
មិនទៅទេ!!! កន្លែងនេះជាជីវិតយើងហើយ។ យើងស៊ូស្លាប់នៅទឹកដីនេះ។
No
The dam destroy Bunong IDENTITY!


មុនការសម្ពោធទំនប់មួយថ្ងៃ ពួកគេបានបិទទ្វារទំនប់ទាំងប្រាំបីដូចដែលគេបានគំរាមមែន។ ទឹកក៏ឡើងជោរជន់
ហើយបានលេបត្របាក់ភូមិយើងទាំងកណ្ដាលអាធ្រាត។
ក្រោកឡើង កូនៗ! ទឹកលិចភូមិអស់ហើយ!
ពួកឯងត្រូវចុះទៅទូកជាបន្ទាន់ណា៎!
ពួកឯងត្រូវចុះទៅទូកជាបន្ទាន់ណា៎!
ពួកគាត់ស្រែកយំដូចអ្វីមួយដែលគាត់ស្រឡាញ់ត្រូវបានគេឆក់យកទៅ។ ដូចមនុស្សគ្រប់គ្នាដែរ
ខ្ញុំខ្សឹកខ្សួលសោកស្ដាយអ្វីៗដែលខ្ញុំបាត់បង់នៅទីនេះ។




ខ្ញុំឃើញក្រុមស្ត្រីៗមមាញឹកដាំស្ល ឯក្រុមបុរសៗមមាញឹកដំឡើងតង់។ ពួកគាត់និយាយគ្នាឮៗ




ពួកគាត់បារម្ភខ្លាចដាច់បាយ តែខ្ញុំបារម្ភជាងគាត់ទៀត ព្រោះខ្លាចមិនបានរៀន និងចាប់យកក្តីស្រមៃនៅ
ពុកម៉ែ ពូមីង! ពេលណាទើបពួកខ្ញុំអាចចូលរៀនវិញ?


រយៈពេលពីរឆ្នាំកន្លងមកនេះ ខ្ញុំឃើញអ្នកភូមិខ្ទះខ្មែងជួយគ្នាធ្វើផ្ទះឱ្យគ្នាម្តងម្នាក់ៗដោយ
មិនទំនេរដៃ។


ឥឡូវយើងអាចរស់នៅ និងគោរពប្រពៃណីដូចមុន ហើយ តែតើពេលណាទើបខ្ញុំអាចទៅសាលាវិញបាន?
កូនៗខ្ញុំក៏ប្រាប់ជារឿយដែរថា ពួកគេនឹកសាលា និងមិត្តភក្តិគេណាស់។
ពួកយើងបានជជែក និងស្នើឱ្យអាជ្ញាធរជួយកសាងសាលាហើយ។ ហើយគេថា គេនឹងពិចារណាលើសំណើរនេះឱ្យពួកយើង។


ខ្ញុំឈ្មោះសុឃឿត។ ខ្ញុំកើតក្នុងគ្រួសារពូនងនៅភូមិស្រែគរ នៃស្រុកសេសាន។ ខ្ញុំនៅតែមានក្តីស្រមៃ ចង់ក្លាយជាគ្រូពេទ្យ។ មិត្តភក្តិខ្ញុំខ្លះចង់ក្លាយជាគ្រូបង្រៀន ហើយខ្លះចង់ធ្វើការងារផ្សេងៗទៀត។ មកទល់ពេលនេះរយៈពេលបួនឆ្នាំហើយដែលខ្ញុំ និងក្មេងៗក្នុងភូមិទន្ទឹងចាំសាលារៀន ដើម្បីបន្តក្តីស្រមៃពួកយើង។